**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
លេខ ១០៤១ ស.ជ.ណ

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ២០១៥

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## សូមគោរពជូន
## សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
## គ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័ន

**កម្មវត្ថុ** : ការកំណត់ឱ្យប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ។

**យោង** : - លិខិតលេខ២៣៧/១៥ កជកខ ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- ចំណារឯកភាពរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥។

ខ្ញុំមានកិត្តិយសសូមគោរពជូន សម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាបថា ដោយការប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ «**ពាន់លាន**» ជាមូលដ្ឋានត្រូវទាល់ត្រឹម$10^{12}$ និង ដោយប្រព័ន្ធលេខអង់គ្លេសបទមានសនិទានភាពជាងប្រព័ន្ធលេខបាលី រាជរដ្ឋាភិបាលបានសម្រេចឱ្យប្រើប្រព័ន្ធលេខខ្ចីពីអង់គ្លេសបទចាប់ពី **ប៊ីលាន**(billion [biljən])គឺ$10^9$ទៅ ដើម្បីឱ្យមានឯកភាពក្នុងការប្រើប្រព័ន្ធលេខក្នុងភាសាខ្មែរ និង ដើម្បីឱ្យប្រព័ន្ធលេខខ្មែរមានសនិទានភាពដូចមានតារាងខាងក្រោម៖

| ចំនួនជាលេខ (០) | ប្រព័ន្ធលេខអង់គ្លេសបទ (១) | | ប្រព័ន្ធលេខខ្មែរខ្ចីពីប្រព័ន្ធលេខអង់គ្លេសបទចាប់ពី$10^9$ទៅ ដោយសម្រួលការអានព្យាង្គចុងជា -*លាន* បែបខ្មែរ (២) | |
|---|---|---|---|---|
| $10^1$ | **Ten** | | ដប់ | |
| $10^2$ | **1 hundred** | | ១រយ | |
| $10^3$ | **1 thousand** | | ១ពាន់ | |
| $10^4$ | 10 thousand | 3 | ១០ពាន់ (១ម៉ឺន) | 3 |
| $10^5$ | 100 thousand | | ១០០ពាន់ (១សែន) | |
| $10^6$ | **1 million** | | ១លាន | |
| $10^7$ | 10 million | 3 | ១០លាន | 3 |
| $10^8$ | 100 million | | ១០០លាន | |

| | | | | |
|---|---|---|---|---|
| $10^{9}$ | **1 billion** | | **១ប៊ីលាន** | |
| $10^{10}$ | 10 billion | 3 | ១០ប៊ីលាន | 3 |
| $10^{11}$ | 100 billion | | ១០០ប៊ីលាន | |
| $10^{12}$ | **1 trillion** | | **១ទ្រីលាន** | |
| $10^{13}$ | 10 trillion | 3 | ១០ទ្រីលាន | 3 |
| $10^{14}$ | 100 trillion | | ១០០ ទ្រីលាន | |
| $10^{15}$ | **1 quadrillion** | | **១ក្វាទ្រីលាន** | |
| $10^{16}$ | 10 quadrillion | 3 | ១០ក្វាទ្រីលាន | 3 |
| $10^{17}$ | 100 quadrillion | | ១០០ក្វាទ្រីលាន | |
| $10^{18}$ | **1 quintillion** | | **១គ្វីនទីលាន** | |
| $10^{19}$ | 10 quintillion | 3 | ១០គ្វីនទីលាន | 3 |
| $10^{20}$ | 100 quintillion | | ១០០គ្វីនទីលាន | |
| $10^{21}$ | **1 sextillion** | | **១សិចទីលាន** | |
| $10^{22}$ | 10 sextillion | 3 | ១០សិចទីលាន | 3 |
| $10^{23}$ | 100 sextillion | | ១០០សិចទីលាន | |
| $10^{24}$ | **1 septillion** | | **១សិបទីលាន** | |
| $10^{25}$ | 10 septillion | 3 | ១០សិបទីលាន | 3 |
| $10^{26}$ | 100 septillion | | ១០០សិបទីលាន | |
| $10^{27}$ | **1 octillion** | | **១អុកទីលាន** | |
| $10^{28}$ | 10 octillion | 3 | ១០អុកទីលាន | 3 |
| $10^{29}$ | 100 octillion | | ១០០អុកទីលាន | |
| $10^{30}$ | **1 nonillion** | | **១ណូនីលាន** | |
| $10^{31}$ | 10 nonillion | 3 | ១០ណូនីលាន | 3 |
| $10^{32}$ | 100 nonillion | | ១០០ណូនីលាន | |
| $10^{33}$ | **1 decillion** | | **១ដេស៊ីលាន** | |
| $10^{34}$ | 10 decillion | 3 | ១០ដេស៊ីលាន | 3 |
| $10^{35}$ | 100 decillion | | ១០០ដេស៊ីលាន | |

| | | | | |
|---|---|---|---|---|
| $10^{36}$ | **1 undecillion** | | ១អាន់ដេស៊ីលាន | |
| $10^{37}$ | 10 undecillion | 3 | ១០អាន់ដេស៊ីលាន | 3 |
| $10^{38}$ | 100 undecillion | | ១០០អាន់ដេស៊ីលាន | |

អាស្រ័យដូចបានគោរពជូនខាងលើ សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាជ្រាប និង ចាត់ចែង ផ្សព្វផ្សាយ អនុវត្ត តាមការគួរ។

សូមសម្តេច ឯកឧត្តម លោកជំទាវ មេត្តាទទួលការគោរពរាប់អានដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

ចម្លងជូន:
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិភាសាខ្មែរ
- ឯកសារ កាលប្បវត្តិ